ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ:**..១៣៦៥..សសណ.ក្ស

ថ្ងៃព្រហស្បតិ៍ ១០ កើត ខែ ភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ជម្រាបជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**កម្មវត្ថុ៖** ករណីសំណើសុំការអនុម័តជាគោលការណ៍ឱ្យប្រើប្រាស់ថ្នាលចុះឈ្មោះ និងរៀបចំបទដ្ឋានគតិយុត្ត ផ្តល់ការទទួលស្គាល់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

**យោង** ៖- លិខិតលេខ ២៥១៨.ឧវបន.គសអសក.លស ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៤ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៤។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលឯកភាពជាគោលការណ៍ដូចខាងក្រោម៖

១- អនុញ្ញាតឱ្យប្រើប្រាស់ថ្នាលឌីជីថល ជាមធ្យោបាយចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

២- អនុញ្ញាតឱ្យរៀបចំអនុក្រឹត្យ ដើម្បីឱ្យការចេញវិញ្ញាបនបត្រទទួលស្គាល់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធដោយថ្នាលឌីជីថល មានអនុភាពគតិយុត្តក្នុងកម្រិតមួយ ដែលក្រសួងស្ថាប័នពាក់ព័ន្ធ អាចទទួលយកបានសម្រាប់ការផ្តល់ការគាំទ្រ និងការផ្តល់សេវានានាជូនអ្នកដែលបានចុះឈ្មោះ។

៣- អនុញ្ញាតឱ្យរៀបចំយុទ្ធនាការចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ បន្ទាប់ពីការចេញអនុក្រឹត្យ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ខួយ ឃុនហ៊ួរ**

**ចម្លងជូន៖**

-ក្រសួងមហាផ្ទៃ

-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ

-ឯកសារ កាលប្បវត្តិ